## ១- ឈ្មោះ និង ការចាត់ថ្នាក់នៃប្រភេទឈើ

ឈ្មោះក្នុងស្រុក : គគីរម្សៅ

ឈ្មោះវិទ្យាសាស្ត្រ : *Hopea odorata* **Roxb.**

គ្រួសារ : **Dipterocarpaceae**

ចំណាត់ថ្នាក់ជាតិ : ឈើលេខ ១

## ២- ការរាយប៉ាយក្នុងធម្មជាតិ និង ទីកន្លែងដុះដាល

គគីរម្សៅមានដើមកំណើតនៅទ្វីបអាស៊ី ភាគខាងត្បូងឈៀងខាងកើត ក្នុងប្រទេស កម្ពុជា ថៃ វៀតណាម ឡាវ ឥណ្ឌា ភូមា និង ម៉ាឡេស៊ី។ គគីរត្រូវបានរកឃើញដុះដោយក្រុមៗ នៅតំបន់ទំនាបព្រៃត្រូពិចដែលក្រាស់ ដីមានជីជាតិ ដីសើមក្បែរផ្លូវទឹក និង កំរឃើញប្រភេទនេះដុះឆ្ងាយពីផ្លូវទឹកណាស់។ នៅប្រទេសឥណ្ឌា គេប្រទះឃើញគគីរដុះនៅក្នុងព្រៃស្រោងបៃតងជានិច្ច រយៈកំពស់ខ្ពស់ឆ្ងាយពីផ្លូវទឹក។ គគីរម្សៅអាចលូតលាស់ក្នុងតំបន់ដីធំទូលាយ ហើយត្រូវការអាកាសធាតុក្តៅសើម មានរដូវច្បាស់លាស់។ កំរិតសីតុណ្ហភាពជាមធ្យមប្រចាំឆ្នាំមានពី ២៥-២៧អង្សាសេ បរិមាណទឹកភ្លៀងមានពី ១៨០០-២២០០ម.ម ក្នុងមួយឆ្នាំ ហើយមានកំរិតសំណើមពី ៧០-៨០%។ ជាញឹកញាប់សង្កេតឃើញដុះនៅតាមផ្លូវទឹកនៃព្រៃស្រោង នៅលើដីខ្សាច់សំបូរមមោត ដីខ្សាច់លាយល្បាយដីឥដ្ឋ និង ដីក្រហម ស្ថិតក្នុងរយៈកំពស់រហូតដល់ ១០០០ម។ ដំណុះរាយប៉ាយក្នុងព្រៃស្រោងបៃតងជានិច្ច ជាពិសេស តំបន់ដែលមានអាកាសធាតុត្រជាក់ ដូចតំបន់ខ្ពង់រាបឥសាន្តនៃប្រទេសកម្ពុជាជាដើម។

## ៣- ការប្រើប្រាស់

ដើមគគីរម្សៅត្រូវបាននិយមដាំតាមដងផ្លូវ ក្នុងវត្តជាលំអ និងសំរាប់ផ្តល់ម្លប់។ ពូជគគីរហាក់ដូចជារុក្ខជាតិមួយដ៏ពិសិដ្ឋ ពីព្រោះនៅប្រទេសកម្ពុជាពីដើមគេមានជំនឿថាមានតែព្រះមហាក្សត្រ និងភិក្ខុសង្ឃទេដែលដាំដើមគគីរបាន។ ដើមឈើមានពណ៌លឿងប្រផេះព្រឿងៗ ជាប្រភេទឈើដែលល្អ និងមានតំលៃសាច់រឹងបង្គួរ ព្រមទាំងធន់នឹងការបំផ្លាញដោយសត្វល្អិត ដូចជាពពួកកណ្តៀរ និងជំងឺ លើសពីនេះធន់នឹងទឹក។ សាច់ឈើមានស្រាយពិបាកញែក ឈើខ្លឹមពណ៌លឿងនៅពេលឈូស និង មានពណ៌លឿងប្រផេះនៅពេលស្ងួត។ ឈើគគីរប្រើក្នុងសំណង់ធ្វើរទេះ ក្តារក្រាល កំណល់ផ្លូវដែក ស្ពាន គ្រឿងសង្ហារឹម រូបចំលាក់ជាពិសេសគឺធ្វើទូកកាណូត ដូចពាក្យស្លោកមួយថា "**គគីរនឹងទឹក ធ្នឹកនឹងដី**" ម្យ៉ាងវិញទៀតគគីរមានតំលៃខ្ពស់នៅលើទីផ្សារអន្តរជាតិទៀតផង។ សំបកគគីរមានជាតិចត់ អាចប្រើជាថ្នាំសំរាប់ព្យាបាលជម្ងឺរាគ ចាស់ៗនិយមហូបសំបកគគីរជាមួយម្លូជំនួស ស្លា អាចធ្វើឱ្យទឹកត្មោតឡើងថ្លា និងមានរសជាតិឆ្ងាញ់។ ម្យ៉ាងទៀតគ្រូឱសថបុរាណប្រើសំបកគគីរផ្សំធ្វើថ្នាំរាក់ស៊ី ធ្មេញ និងសំរាប់ព្យាបាលជំងឺនោមមិនដឹងខ្លួន។

## ៤- លក្ខណៈរុក្ខសាស្ត្រ

- **ដើម:** ជាប្រភេទឈើមានស្លឹកបៃតងជានិច្ច និង មានទំហំធំ មានអង្កត់ផ្ចិត ៦០-១២០ ស.ម។ តួដើមត្រង់ពី ១០-១៥ម ជួនកាល ២៥ម និង មានកំពស់ដល់ចុងពី ២០-៣៥ម ពេលខ្លះដល់ ៤៥ម។ សំបកមានពណ៌ត្នោត-ខ្មៅព្រឿងៗ ប្រេះ និងគគ្រាតៗ តាមបណ្តោយដើម។ សំបកខាងក្នុងមានពណ៌ត្នោត-ក្រហមព្រឿងៗ និង មានសរសៃច្រើន។

- **ស្លឹក:** ស្លឹកមានរាងពងក្រពើទ្រវែង ជួនកាលរាងដូចចុងលំពែង ដែលមានប្រវែង ៨-១៤ ស.ម និង ទទឹង ៣-៦ ស.ម។ ចុងស្លឹកខ្លី ហើយស្រួច ឬ ទាលស្រាលនៅត្រង់គល់ ស្តួចចុង គ្មានរោម។ ទ្រនុងទីពីរមានលក្ខណៈខូចដែលមានរោមស្រមូវនៅត្រង់គល់ផ្នែកខាងក្រោមទ្រនុងទីពីររាងជាជណ្តើរ ទងស្លឹកស្តួចខ្មៅនៅពេលស្ងួត។

## ៥- ការពិពណ៌នាអំពីផ្កា ផ្លែ

- **ផ្កា:** ផ្កានៅខាងចុង ឬនៅលើអ័ក្សជា panicle ប្រវែងពី ៥-៧ស.ម មានរោមប្រផេះ។ មែកផ្កាមានចំនួន ១១-១២ ហើយមែកនីមួយៗមានផ្កា ៤-៦ ស្ទើរអង្គុយ។ ទំរត្របកផ្កាមាន៥ខាងក្រៅមានរោមទាំងសងខាង ខាងក្នុងគ្មានរោមទេ។ ត្របកផ្កាមាន ៥ ដែលកោងដូចដងធ្នូ និងពាសដោយរោម នៅខាងក្រៅកេសរឈ្មោលមានចំនួន១៥ អូវែរាងពងក្រពើ ។

- **ផ្លែ:** ផ្លែមានរាងពងក្រពើទំហំ ៥ម.ម ខ ៦ម.ម ស្ទើរស្រួច និងមានស្លាប ២ ដែលមានប្រវែង ៥-៦ ស.ម និងទទឹង ១-២ស.ម។ ក្នុងមួយផ្លែមានគ្រាប់មួយ។ គ្រាប់ជាពហុអំប្រិយ៉ុង ដែលជាមធ្យមមានអំប្រិយ៉ុង ៤ក្នុងមួយគ្រាប់។



## ៦- រដូវចេញផ្កា ផ្លែ

រដូវចេញផ្ការបស់គគីរម្សៅគឺនៅខែ កុម្ភៈ-មិនា និងផ្លែនៅខែមេសា-ឧសភា ។

## ៧- ការប្រមូលគ្រាប់ពូជ

គ្រាប់ពូជគួរត្រូវប្រមូលពីលើដើមមេធំៗ ដែលមានអាយុលើសពី ១៥ឆ្នាំ។ គ្រាប់ទុំល្អនៅពេលដែលស្លាបនៃផ្លែប្រែពណ៌ទៅជាពណ៌ត្នោតចាស់ និងត្របកនៃស្រទាប់ផ្លែប្រែពណ៌ពីបៃតងមកលឿង។ លក្ខណៈទាំងនេះ ជាចំនុចសំខាន់ណាស់ក្នុងការប្រមូលគ្រាប់ពូជឱ្យបានល្អ ចៀសវាងការប្រមូលគ្រាប់ដែលមិនទាន់ទុំ។ ផ្លែត្រូវបានប្រមូលដោយផ្ទាល់ពីដើម ដោយការឡើង ឬ ដោយការអង្រួន់មែកដោយមានក្រាលក្រណាត់កៅស៊ូនៅពីក្រោមដើម។ ការប្រមូលគ្រាប់នៅក្នុងព្រៃធម្មជាតិ ដោយការក្រាលក្រណាត់កៅស៊ូពីក្រោមដើម នោះអាចចៀសវាងបាននូវគ្រាប់ដែលមានគុណភាពទាប និងជាញឹកញាប់គ្រាប់ពូជទាំងនោះត្រូវសត្វល្អិតបំផ្លាញ ។

## ៨- លទ្ធកម្មគ្រាប់ពូជ និង បញ្ហជំងឺ

គ្រាប់ស្រស់មានផ្ទុកសំណើមខ្ពស់ ហើយមិនធន់នឹងការបញ្ចុះជាតិទឹកទេ។ គ្រាប់ពូជអាចរក្សាទុកក្នុងស្បោងប្លាស្ទិចមិនបិទ ដោយគ្រាន់តែបត់មាត់ស្បោងប៉ុណ្ណោះ ហើយចៀសវាងការត្រូវពន្លឺថ្ងៃក្នុងពេលដឹកជញ្ជូន ឬ ផ្ទុកក្នុងឃ្លាំងបណ្តោះអាសន្ន។ ជាការល្អបំផុត គ្រាប់ដែលបេះបានភ្លាមត្រូវយកទៅបណ្តុះភ្លាម។ គ្រាប់ពូជងាយនឹងរងនូវការបំផ្លាញពីសត្វខ្ចុតណាស់ ជាពិសេសនៅពេលផ្លែធ្លាក់ដល់ដី ឬពេលស្តុកទុក គ្រាប់ក៏អាចឆ្លងជំងឺផ្សិតដែរ។ គ្រាប់ពូជស្រស់ៗដែលមានភាគ

រយនៃសំណើមប្រមាណ ៥០% ជាធម្មតាការចេញពន្លកមានប្រមាណ ១០០%។ ប៉ុន្តែបើសំណើមថយចុះ នោះលទ្ធភាពដុះពន្លកក៏ថយចុះដែរ។ ការសាកល្បងថ្មីមួយបង្ហាញថា នៅពេលដែលគ្រាប់ពូជត្រូវបានសំងួតសំណើមដល់ ៤៤% ការចេញពន្លកនឹងធ្លាក់ពី ១០០% មកត្រឹម ៨៦%, នៅកំរិតសំណើម ៣១% ការចេញពន្លកមាន ៧៤% ហើយនៅកំរិតសំណើម ២៣% គ្រាប់ពូជត្រូវខូចទាំងអស់។ ក្រោយពីការស្តុកគ្រាប់ទុករយៈពេល ១៦ សប្តាហ៍ ដំណុះមានត្រឹមតែ ៥០% និងក្រោយការស្តុករយៈពេល២០សប្តាហ៍ នោះមានគ្រាប់ពូជមួយចំនួនតូចប៉ុណ្ណោះដែលនៅរស់។ តាមលំនាំដូចគ្នានេះដែរ ចំពោះគ្រាប់ពូជដែលមានសំណើម ៣៧% និង ៤៨% និងថែរក្សាទុកនៅសីតុណ្ហភាព ១៦អង្សាសេ និង២៥អង្សាសេ ផ្សេងគ្នា គឺឃើញថាគ្រាប់ដែលទុកនៅសីតុណ្ហភាព ១៦អង្សាសេ ហាក់ដូចជាប្រសើរជាងបន្តិច ដោយសារតែគ្រាប់មានការចេញពន្លកក្នុងពេលស្តុកទុកតិចជាង។ ការសាកល្បងផ្សេងទៀតបានបង្ហាញថា គ្រាប់ពូជមិនធន់នឹងបំរែបំរួលសីតុណ្ហភាពទេ និងបាត់បង់លទ្ធភាពរស់យ៉ាងឆាប់រហ័សពេលរក្សាទុកនៅសីតុណ្ហភាព ១០អង្សាសេ។ មានការផ្តល់អនុសាសន៍ថា ប្រសិនបើស្តុកទុករយៈពេលតិចជាងមួយខែ គ្រាប់ពូជត្រូវដាក់ក្នុងស្បោងប្លាស្ទិច ដោយគ្រាន់តែបត់មាត់ស្បោង ដោយទុកឱ្យមានខ្យល់ចេញចូល និងរក្សាទុកក្នុងសីតុណ្ហភាពក្នុងបន្ទប់ធម្មតា។ សំរាប់ការស្តុកទុកលើសពីមួយខែ ត្រូវសំងួតគ្រាប់ពូជឱ្យសំណើមធ្លាក់ចុះដល់ប្រមាណ ៤០% ហើយស្តុកទុកនៅសីតុណ្ហភាព ១៥អង្សាសេ ក្នុងស្បោងប្លាស្ទិចដោយគ្រាន់តែបត់មាត់ផង់។

### ៩- ការសាកបណ្តុះគ្រាប់ពូជ

គ្រាប់គគីរមិនមានភាពសំងំ និង មិនចាំបាច់ធ្វើប្រព្រឹត្តិកម្មគ្រាប់ទេ។ ដំណុះនៃគ្រាប់កើនឡើង ដោយគ្រាន់តែយកគ្រាប់ទៅត្រាំទឹករយៈពេល ៨ម៉ោងមុនពេលសាបព្រោះ។ ចំពោះការសាកល្បងនៅក្នុងមន្ទីរពិសោធន៍ គ្រាប់ពូជ (ផ្លែដែលកាត់ស្លាបរួច) ត្រូវបានបណ្តុះក្នុងដីខ្សាច់នៅសីតុណ្ហភាពបន្ទប់ធម្មតា។ គ្រាប់គគីរម្សៅត្រូវសាបនៅក្នុងថ្នាលបណ្តុះដោយប្រើដីលាយអង្កាម ហើយរោយចំបើងគ្របពីលើ។ បន្ទាប់ពីកូនសំណាបដុះបានពី ៣០-៦០ថ្ងៃ ត្រូវដកកូនសំណាបចេញពីថ្នាលយកទៅស្ទូងនៅក្នុងថង់ប្លាស្ទិចច្រកដីដែលរៀបចំស្រាប់។ ត្រូវទុកកូនឈើឱ្យនៅក្រោមម្លប់ ៥០% ទើបដុះលូតលាស់ល្អ។



### ១០- ការផលិតកូនឈើ

បន្ទាប់ពីមានអាយុ ១-២ឆ្នាំ កូនគគីរម្សៅអាចយកចេញទៅដាំបាន។



### ១១- ការដាំកូនឈើ

ដោយកូនគគីរម្សៅត្រូវការម្លប់ ទើបមានការលូតលាស់យឺតនៅក្នុងរយៈពេល៣ឆ្នាំដំបូង។ ជាការល្អបំផុតក្នុងការដាំដើមគគីរម្សៅត្រូវដាំនៅចន្លោះប្រឡាយទឹកដើម្បីអោយកូនឈើដុះលូតលាស់បានល្អ។

### ១២- ឯកសារយោង


- Joeker D., 2000. SEED LEAFLET No. 49, Danida Forest Seed Centre.
- Forest Inventory and Planning Institute,1996.Vietnam Forest Trees, Page 137.
- ប៉ែន វុទ្ធី។ ដើមគគីរម្សៅ។ ទស្សនាវដ្តី រុក្ខា-ប្រមាញ់ លេខ ២៣ ឆមាសទី២ ឆ្នាំ២000។



រដ្ឋបាលព្រៃឈើ

គំរោងគ្រាប់ពូជឈើកម្ពុជា

DANIDA

អាគារលេខ ៤០ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ

ទូរស័ព្ទ: ០២៣ ២១៥ ០៣៤ Email: ctsp@online.com.kh




# គគីរម្សៅ

## *Hopea odorata* Roxb.